00375613

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 15 / 09 / 2009
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

001/18-07-2007-ECCC/TC
E1/42

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 16 / 09 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ
# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះករណី "ឌុច"
# សាធារណៈ

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៩ -ថ្ងៃជំនុំជម្រះទី ៣៧

រៀបចំដោយ: សែ កុលវុឌ្ឍី និង Natacha WEXELS-RISER

| |
|---|
| **កំណត់ហេតុអ្នកចូលរួម** |
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម ធូ មណី |
| ចៅក្រមបម្រុង៖ ចៅក្រម យូរ ឧត្តរា (បម្រុង) និង ចៅក្រម Claudia FENZ (បម្រុង) |
| ក្រឡាបញ្ជី៖ លោក Crippa MATTEO, លោកស្រី សែ កុលវុឌ្ឍី, កញ្ញា Natacha Wexels-Riser, លោក លឹម ស៊ុយហុង |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក តាន់ សេណារ៉ុង, លោក William Smith, លោក ពេជ្រ សម្បត្តិ, លោក Zachery Lampell, លោក ជា ផល្លា |
| ជនជាប់ចោទ៖ លោក កាំង ហ្គេចអ៊ាវ ហៅ ឌុច |

| |
|---|
| មេធាវីជនជាប់ចោទ៖ លោក ការ សាវុត្ថ, លោក François Roux(អវត្តមាន), លោកស្រី Marie-Paule Canizares, លោកស្រី Heleyn Unac,លោក ចាន់ រ៉ាវុធ, កញ្ញា Lucile Nattiez |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី Silke Studzinsky, លោក គង់ ពិសី, លោកស្រី Martine Jacquin, កញ្ញា ម៉ុច សុវណ្ណារី, កញ្ញា ទី ស្រីនណា, លោក Alain Werner, លោក ហុង គឹមសួន |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក កួវ កែវរតនៈ |
| ផ្សេងៗ៖ លោក ឡាយ ណារ៉ា, លោក Scott Bywater, លោក ខែម លីនដារីតា, លោកស្រី Maryvonne Maniacky, កញ្ញា Aline Briot |

| **<u>ពេលវេលាទូទៅរបស់តុលាការ៖</u>** | | |
|---|---|---|
| ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៩ | ចាប់ផ្តើមម៉ោង៖ ៩.០០ | បញ្ចប់ម៉ោង៖ ១៦.០០ |
| ការពន្យាពេលសវនាការ | ចាប់ផ្តើមម៉ោង៖៩.៤០ | បញ្ចប់ម៉ោង៖១០.២៥ |
| សម្រាកព្រឹក | ចាប់ផ្តើមម៉ោង៖១១.២០ | បញ្ចប់ម៉ោង៖១១.៣៥ |
| សម្រាក | ចាប់ផ្តើមម៉ោង៖១២.១៥ | បញ្ចប់ម៉ោង៖ ១៣.៣០ |
| សម្រាកល្ងាច | ចាប់ផ្តើមម៉ោង៖ ១៤.៥០ | បញ្ចប់ម៉ោង៖ ១៥.១៥ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៤ ម៉ោង និង ២០នាទី |

| **<u>កិច្ចដំណើរការនីតិវិធីផ្សេងទៀត</u>** | | | |
|---|---|---|---|
| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
| ការស្នើសុំដាក់កិច្ចសម្ភាសន៍ នង ចាន់ផល ដែលធ្វើដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៩ ទៅក្នុងសំណុំរឿង និងស្នើសុំបង្ហាញខ្សែវីដេអូខ្លី E5/10 ឧបសម្ព័ន្ធក (V00271181, V00271182) ទៅសាក្សី នង ចាន់ផល។ ការពិភាក្សាដេញដោល | សហព្រះរាជអាជ្ញា<br>អង្គជំនុំជម្រះ<br>មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី១<br>មេធាវីការពារក្តី | ០៩.០៣ | ៩.៤០ |
| សេចក្តីសម្រេចទៅនឹងសំណើរបស់សហព្រះ | អង្គជំនុំជម្រះ | ១០.២៦ | ១០.៣[illegible] |

| | | | |
|---|---|---|---|
| រាជអាជ្ញា | | | |
| ការតាំងសំណួរទៅសាក្សី នង ចាន់ផលទាក់ទងនឹងអង្គហេតុនៃប្រតិបត្តិការណ៍មន្ទីរស២១ | អង្គជំនុំជម្រះ | ១០.៣៥ | ១៣.៤៩ |
| ការតាំងសំណួរទៅសាក្សី នង ចាន់ផលទាក់ទងនឹងអង្គហេតុនៃប្រតិបត្តិការណ៍មន្ទីរស២១ | សហព្រះរាជអាជ្ញា | ១៣.៤៩ | ១៤.១០ |
| ការតាំងសំណួរទៅសាក្សី នង ចាន់ផលទាក់ទងនឹងអង្គហេតុនៃប្រតិបត្តិការណ៍មន្ទីរស២១ | មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី១(១៤.១២ ដល់១៤.២៩)ក្រុមទី៣(១៤.៣០ ដល់១៤.៤១)ក្រុមទី៤(១៤.៤១ ដល់១៤.៤៦) | ១៤.១២ | ១៤.៤៦ |
| ការតាំងសំណួរបន្ថែមទៅលើសាក្សី នង ចាន់ផល ដោយអង្គជំនុំជម្រះ | អង្គជំនុំជម្រះ | ១៤.៤៨ | ១៤.៥០ |
| សំណួររបស់សាក្សី នង ចាន់ផល ទៅជនជាប់ចោទ | អង្គជំនុំជម្រះ | ១៥.១៧ | ១៥.២១ |
| ការតាំងសំណួរបន្ថែមទៅជនជាប់ចោទទាក់ទងនឹងសក្ខីកម្មរបស់សាក្សី នង ចាន់ផល និងការពិភាក្សាការដេញដោល | អង្គជំនុំជម្រះ | ១៥.២៣ | ១៥.៤៩ |
| ការតាំងសំណួរទៅសាក្សីនង ចាន់ផលទាក់ទងនឹងអង្គហេតុនៃប្រតិបត្តិការណ៍មន្ទីរស២១ | មេធាវីការពារក្តី | ១៥.៤៩ | ១៥.៥៩ |

<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>

**សំណើរបស់សហព្រះរាជអាជ្ញា**

- សហព្រះរាជអាជ្ញាបានស្នើសុំដាក់កិច្ចសម្ភាសន៍របស់សាក្សី នង ចាន់ផល ដែលបានធ្វើនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៩ ទៅក្នុងសំណុំរឿង និងស្នើសុំឱ្យបង្ហាញខ្សែវីដេអូខ្លីE5/10 ឧបសម្ព័ន្ធក (V00271181,V00271182) ទៅឱ្យសាក្សីនង ចាន់ផល។
- មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី១ និង ៣ បានគាំទ្រចំពោះសំណើក្នុងការបង្ហាញ

ខ្សែវីដេអូខ្លីដល់សាក្សី និងបានបញ្ជាក់ថាពួកគេទើបតែទទួលបានកិច្ចសម្ភាសន៍នេះកាលពីម្សិលមិញតែប៉ុណ្ណោះ។

- មេធាវីការពារក្តីបានបដិសេធនូវសំណើទាំងពីរនេះ។

**សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងកិច្ចសម្ភាសន៍របស់នង ចាន់ផល**

អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចដោយកត់សម្គាល់ថាអង្គហេតុទាក់ទងនឹងកិច្ចសម្ភាសន៍នេះត្រូវបានដាក់នៅក្នុងសំណុំរឿង ហើយបដិសេធនូវសំណើសុំក្នុងការដាក់នូវចំពោះមុខអង្គជំនុំជម្រះផ្អែកតាមវិធាន ៨៧.៤។

**ការពិភាក្សាដេញដោល និងសេចក្តីសម្រេចលើសំណើសុំក្នុងការបង្ហាញខ្សែវីដេអូខ្លីពីរ**

អង្គជំនុំជម្រះកត់សម្គាល់ថាខ្សែវីដេអូនេះត្រូវបានដាក់នូវក្នុងសំណុំរឿងរួចហើយ។ អង្គជំនុំជម្រះបានបញ្ជាក់ជាមួយសហព្រះរាជអាជ្ញាថាតើមូលហេតុជាក់លាក់ដែលខ្លួនបានលើកឡើងសម្រាប់ស្នើសុំប្រើប្រាស់ខ្សែវីដេអូនេះជាភស្តុតាងនោះនៅរក្សារដដែលឬទេ។ សហព្រះរាជអាជ្ញាបានចង្អុលបង្ហាញថានេះគឺជាខ្សែវីដេអូដ៏ល្អដែលបង្ហាញពីទិដ្ឋភាពនៅមន្ទីរស២១ក្នុងសម័យនោះ។ ខ្សែវីដេអូនេះផ្តល់នូវភស្តុតាងដ៏ល្អបំផុតនៅក្នុងលក្ខខណ្ឌដែលថាប្រជាជនណាមួយដែលត្រូវបានរក្សាទុក ពីការសម្លាប់នៅស២១ ចំនួនប្រជាជនដែលត្រូវបានសម្លាប់ ពេលដែលខ្មែរក្រហមបានចាកចេញពីស២១ ស្ថានភាព នៃការឃុំខ្លួន ឧបករណ៍ធ្វើទារុណកម្ម និងរូបភាពនៃឧបករណ៍ទាំងនោះ។ ខ្សែវីដេអូនេះមានភាពពាក់ព័ន្ធគ្រប់ផ្នែកទាំងអស់នៅក្នុងសំណុំរឿងនេះ។ អង្គជំនុំជម្រះចង្អុលបង្ហាញថា អង្គជំនុំជម្រះមិនទាន់បានសម្រេចថាតើត្រូវដាក់ខ្សែវីដេអូនេះមកដេញដោលនៅចំពោះមុខអង្គជំនុំជម្រះនោះទេ អង្គជំនុំជម្រះនឹងចេញសេចក្តីសម្រេចនៅពេលក្រោយទាក់ទងនឹងការបង្ហាញខ្សែវីដេអូខ្លីពីរឈុតនេះ។

**ការតាំងសំណួរទៅសាក្សី នង ចាន់ផល ទាក់ទងនឹងអង្គហេតុនៃប្រតិបត្តិការណ៍មន្ទីរស២១ រួម បញ្ចូលជើងឯក ដោយអង្គជំនុំជម្រះ**

- អង្គជំនុំជម្រះបានតាំងសំណួរទៅសាក្សី នង ចាន់ផល ទាក់ទងនឹងអង្គហេតុនៃប្រតិបត្តិការណ៍មន្ទីរស២១ រួមបញ្ចូលទាំងជើងឯក។

**ការតាំងសំណួរទៅសាក្សី នង ចាន់ផល ទាក់ទងនឹងអង្គហេតុប្រតិបត្តិការណ៍មន្ទីរស២១ រួមបញ្ចូលទាំងឯក ដោយសហព្រះរាជអាជ្ញា និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

- សហព្រះរាជអាជ្ញា និង មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី១,៣,៤ បានតាំងសំណួរទៅសាក្សី នង ចាន់ផល ទាក់ទងនឹងអង្គហេតុនៃប្រតិបត្តិការណ៍មន្ទីរស២១ រួមបញ្ចូលទាំងជើងឯក។

**ការតាំងសំណួរបន្ថែមទៅជនជាប់ចោទទាក់ទងនឹងសក្ខីកម្មរបស់សាក្សី នង ចាន់ផល និងការពិភាក្សាដេញដោល**

អង្គជំនុំជម្រះបានតាំងសំណួរបន្ថែមទៅជនជាប់ចោទទាក់ទងនឹងសក្ខីកម្មរបស់សាក្សី នង ចាន់ផល និងបានបង្ហាញសាក្សីនូវខ្សែវីដេអូខ្លី V00271181 (០៧ នាទី និង ០៩ វិនាទី)

**ការតាំងសំណួរទៅសាក្សី នង ចាន់ផល ទាក់ទងនឹងអង្គហេតុប្រតិបត្តិការណ៍មន្ទីរស២១ រួមបញ្ចូលទាំងឯក ដោយមេធាវីការពារក្តី**

- មេធាវីការពារក្តីបានតាំងសំណួរទៅសាក្សី នង ចាន់ផល ទាក់ទងនឹងអង្គហេតុនៃប្រតិបត្តិការណ៍មន្ទីរស២១ រួមបញ្ចូលទាំងជើងឯក។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧.៣**

| លេខយោងរបស់អជសដ | លេខយោងរបស់កសចស | ឈ្មោះ/ការអធិប្បាយ | ចំណាត់ថ្នាក់ឯកសារ (សំងាត់បំផុត សំងាត់ ឬសាធារណៈ) | កំណត់សម្គាល់ |
|---|---|---|---|---|
| E3/16 | D45/1/8 | រូបភាពពីលើអាកាសបង្ហាញពីទីតាំងមន្ទីរស២១ | សាធារណៈ | 00189137-00189137 មាននៅក្នុងE3រួចហើយ |
| E5/12/1 | គ្មាន | ក្រុមទី១បញ្ជីឈ្មោះសាក្សីបន្ថែមរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាមួយនិងឧបសម្ព័ន្ធមួយចំនួន | សម្ងាត់ | 00291146,00289887 |

កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី- ០២ កក្កដា ២០០៩ /សាធារណៈ

<u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u>

**១-សេចក្តីសម្រេចទាក់ទងនឹងកិច្ចសម្ភាសន៍របស់នង ចាន់ផល**

-អង្គជំនុំជម្រះកត់សម្គាល់ថាការដាក់កិច្ចសម្ភាសន៍របស់ នង ចាន់ផល ដែលបានធ្វើដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៨ ត្រូវបានដាក់នៅក្នុងសំណុំរឿងរួចហើយ។

-អង្គជំនុំជម្រះបដិសេធសំណើរបស់សហព្រះរាជអាជ្ញាក្នុងការដាក់ឯកសារនេះមកដេញដោលនៅចំពោះមុខអង្គជំនុំជម្រះផ្អែកតាមវិធាន ៨៧.៤ នៃវិធានផ្ទៃក្នុង។

-មូលហេតុ៖ កិច្ចសម្ភាសន៍នេះត្រូវបានធ្វើឡើងកាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៨ ហើយសហព្រះរាជអាជ្ញា បានទទួលកិច្ចសម្ភាសន៍នេះជាភាសាខ្មែរជាច្រើនខែមកហើយ ប៉ុន្តែទើបតែយកកិច្ចសម្ភាសន៍នេះមកដាក់ក្នុងសំណុំរឿងនៅក្នុងថ្ងៃនេះ។ ដែលមិនអាចឲ្យភាគី ជាពិសេសមេធាវីការពារក្តីមិនមានលទ្ធភាពក្នុងការការពារកូនក្តីរបស់ខ្លួនបាន។

២-បង្គាប់ឲ្យនាំជនជាប់ចោទត្រឡប់ទៅមន្ទីរឃុំឃាំងវិញ និងបង្គាប់ឲ្យនាំគាត់ត្រឡប់មកកាន់សាលសវនាការវិញ នៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៨ ។

<u>ដីកាសម្រាប់ការលើកវារកាលសវនាការ</u>

ការពន្យាពេលសវនាការ៖ អង្គជំនុំជម្រះបានសម្រាកធ្វើការពិភាក្សាទៅលើសំណើសុំរបស់សហព្រះរាជអាជ្ញា អស់រយៈពេល ៤៥នាទីនៅពេលព្រឹក។

សវនាការនឹងបន្តទៅថ្ងៃច័ន្ទ ទី០៦ ខែកក្កដា ឆ្នាំ២០០៨ វេលាម៉ោង៩.០០ ព្រឹក ។ NWR

ភ្នំពេញ ថ្ងៃទី ០២ ខែ កក្កដា ឆ្នា ២០០៨

ក្រឡាបញ្ជី ក្រឡាបញ្ជី

**សែ កុលទុន្នី** Natacha WEXELS-RISER